# ឧបសម្ព័ន្ធ ២

# ការប្រៀបធៀបរវាង ការជំនុំជម្រះក្តីរបស់ អៀង សារី នាឆ្នាំ ១៩៧៩ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យជំនុំជម្រះ

| **ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ** | **សាលក្រមឆ្នាំ ១៩៧៩** |
|---|---|
| កម្មវត្ថុនៃផែនការឧក្រិដ្ឋកម្មរួមនេះគឺ ការធ្វើទុកបុកម្នេញដែលមានលក្ខណៈជាប្រព័ន្ធ មកលើក្រុមជាក់លាក់មួយចំនួននៅក្នុងចំណោមប្រជាជនកម្ពុជា ដោយលើកឡើងថាដើម្បីបង្កើតនូវសង្គមមួយដែលគ្មានវណ្ណៈ គ្មានសាសនា និងជាតិពន្ធុស្មើភាពទាំងអស់ លុបបំបាត់ចោលរាល់ភាពផ្សេងគ្នានៃជាតិពន្ធុ ជនជាតិ សាសនា ពូជសាសន៍ វណ្ណៈ និងវប្បធម៌។<br>**#៦** | ការអនុវត្ត នូវផែនការណ៍សម្លាប់រង្គាលដោយមានខ្សែរយៈប្រព្រឹត្តទៅលើប្រជាជនគ្រប់ស្រទាប់គ្រប់ប្រភេទ ក្នុងសភាពសាហាវឃោឃៅបំផុត៖ ការសម្លាប់រង្គាលគ្មានរើសមុខទៅលើនាយទាហាន ឬពលទាហាននៃរបបចាស់ សម្លាប់រង្គាលនូវបញ្ញាវ័ន្តគ្រប់ជាន់ថ្នាក់ សម្លាប់រង្គាលទាំងមនុស្ស ទាំងចលនាដែលពួកគេយល់ថាប្រឆាំងនឹងពួកគេ។<br>**#I** |
| អ្វីមួយ ឬជនណាក៏ដោយ ដែលបក្សកុម្មុយនីស្តកម្ពុជាយល់ថាជាការគំរាមកំហែង ឬជាឧបសគ្គដល់គោលនយោបាយនិងមនោគមវិជ្ជារបស់ខ្លួន នឹងត្រូវបានសម្លាប់ឬបំផ្លាញចោល រួមមានសាសនា ជាតិពន្ធុផ្សេងគ្នា “វណ្ណ◌ៈសក្តិភូមិ” “វណ្ណៈមូលធន” និង “វណ្ណៈគហបតី” និងជនទាំងអស់ដែលគេយល់ថាជាជនក្បត់នៅក្នុងចំណោមប្រជាជនឬនៅក្នុងចំណោមកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា។<br>**#៦** | ការអនុវត្ត នូវផែនការណ៍សម្លាប់រង្គាលដោយមានខ្សែរយៈប្រព្រឹត្តទៅលើប្រជាជនគ្រប់ស្រទាប់គ្រប់ប្រភេទ ក្នុងសភាពសាហាវឃោឃៅបំផុត៖ ការសម្លាប់រង្គាលគ្មានរើសមុខទៅលើនាយទាហាន ឬពលទាហាននៃរបបចាស់ សម្លាប់រង្គាលនូវបញ្ញាវ័ន្តគ្រប់ជាន់ថ្នាក់ សម្លាប់រង្គាលទាំងមនុស្ស ទាំងចលនាដែលពួកគេយល់ថាប្រឆាំងនឹងពួកគេ។<br>**#I** |
| ការបដិសេធនូវសិទ្ធិជាមូលដ្ឋានដល់សមាជិកនៃប្រជា-ជនដែលមិនមែនត្រូវបានកំណត់អត្តសញ្ញាណថាជាសមាជិកក្នុងគោលដៅនៃក្រុមទាំងនេះ មានដូចជាសិទ្ធិមានសេរីភាព សន្តិសុខបុគ្គលនិងទ្រព្យសម្បត្តិ សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិយោបល់ គំនិត សតិសម្បជញ្ញៈ និងសាសនា និងសិទ្ធិមានគ្រួសារនិងជីវិតផ្ទាល់ខ្លួន ។<br>**#៧** | ក្នុងរយៈពេល៤ឆ្នាំដែលពួកគេកាន់អំណាច បនប៉ុល ពត អៀង សារី បានប្រើវិធីធ្វើទារុណកម្ម និងសម្លាប់មនុស្សយ៉ាងព្រៃផ្សៃបំផុត។<br>**#VIII** |
| ការបង្កើតនូវមន្ទីរសន្តិសុខ ជំរុំការងារពលកម្មធ្វើដោយ | ការបង្ខំប្រជាជនឲ្យចូល“សហករណ៍” ដែលជាជំរុំ |

| | |
|---|---|
| បង្ខំ មណ្ឌលលត់ដំ និងសហករណ៍នានាជាច្រើន<br>#៩ | ប្រមូលផ្តុំកន្លែងក្លាយ ដែលប្រជាជនត្រូវបានបង្ខំឲ្យធ្វើការនិងរស់ក្នុងលក្ខណៈវិនាសអន្តរាយលើរូបរាងកាយនិងស្មារតី សម្លាប់រង្គាល ឬបានស្លាប់មួយចំនួនធំ។<br>#IV |
| នៅក្នុង ឬនៅមុនខែមេសា ឆ្នាំ១៩៧៥ ជានយោបាយដែលបានគិតទុកជាមុនរបស់បក្សកុម្មុយនីស្តកម្ពុជា ប្រជាជនដែលរស់នៅតំបន់ប្រជុំជន ដូចជា ភ្នំពេញ កំពង់ចាម កំពង់សោម ព្រៃវែង បាត់ដំបង ពោធិ៍សាត់ និងសៀមរាប ត្រូវបានបង្ខំឲ្យផ្លាស់ទៅជនបទ ជាកន្លែងដែលពួកគេត្រូវបានបង្ខំឲ្យធ្វើពលកម្មជាទម្ងន់ នៅតាមសហករណ៍ជនបទនានា<br>#១១ | ការបណ្តេញប្រជាជនចេញពីក្រុងភ្នំពេញ ពីទីប្រជុំជន និងជនបទដែលរំដោះបាន ការបំបែកនិងបង្កការឈឺចាប់ដល់ក្រុមគ្រួសារនិងរចនាសម្ព័ន្ធសង្គម ការសម្លាប់រង្គាល និងការបង្កើតស្ថានភាពគ្រោះថ្នាក់ដល់ជីវិត។<br>#III<br>ការបង្ខំប្រជាជនឲ្យចូល "សហករណ៍"<br>#IV |
| បក្សកុម្មុនីស្តកម្ពុជាបានអនុវត្តការរើសអើងមានលក្ខណៈជាប្រព័ន្ធ ប្រឆាំងនឹងក្រុមដែលជាគោលដៅនានា រួមទាំង៖<br>- អតីតមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ រួមទាំងមន្ត្រីរាជការស៊ីវិល អតីតបុគ្គលិកយោធា និងក្រុមគ្រួសាររបស់ពួកគេ<br>- ពួកសក្តិភូមិ ពួកមូលធន និងពួកគហបតី<br>- ប្រជាជនថ្មី<br>- ពុទ្ធសាសនិកជន<br>- ជនជាតិភាគតិចចាមនិងអ្នកកាន់សាសនាអ៊ីស្លាម<br>- ជនជាតិភាគតិចវៀតណាមនិងអ្នកកាន់សាសនាវៀតណាម<br>- សមាសភាពមិនល្អដែលត្រូវគេសង្ស័យ។<br>#១២ | ការសម្លាប់រង្គាលដោយមិនរើសមុខ ទៅលើនាយទាហាននិងអ្នករដ្ឋការរបស់របបមុន ព្រមទាំងគ្រួសាររបស់គេ<br>#I.១<br>ការសម្លាប់រង្គាលបញ្ញវ័ន្ត<br>#I.២<br>ការបណ្តេញប្រជាជនចេញពីក្រុងភ្នំពេញ ពីទីប្រជុំជន និងជនបទដែលរំដោះបាន ការបំបែកនិងបង្កការឈឺចាប់ដល់ក្រុមគ្រួសារនិងរចនាសម្ព័ន្ធសង្គម ការសម្លាប់រង្គាល និងការបង្កើតស្ថានភាពគ្រោះថ្នាក់ដល់ជីវិត។<br>#III<br>ការសម្លាប់រង្គាលមេដឹកនាំសាសនា សាសនិកជន ការលុបបំបាត់សាសនា |

| | |
|---|---|
| | #II<br>ការលុបបំបាត់សាសនា ការសម្លាប់ផុតពូជដែលមានលក្ខណៈជាប្រព័ន្ធលើជនជាតិភាគតិច<br>#II<br>ការលុបបំបាត់សាសនា ការសម្លាប់ផុតពូជដែលមានលក្ខណៈជាប្រព័ន្ធលើជនជាតិភាគតិច<br>#II<br>ការបង្ក្រាបដែលមានលក្ខណៈធ្ងន់ធ្ងរ និងការសម្លាប់រង្គាលជាលក្ខណៈប្រព័ន្ធលើបុគ្គលនិងអង្គការដែលសង្ស័យថាប្រឆាំងនឹងរបបនេះ។<br>**#I.៣** |
| បក្សកុម្មុនីស្តកម្ពុជា បានស្រាវជ្រាវរកយ៉ាងសកម្មចំពោះអតីតមន្ត្រីរបបសាធារណរដ្ឋខ្មែរ និងអ្នករដ្ឋការដើម្បីប្រហារជីវិត។ ជាដំបូង គោលនយោបាយនេះគឺសម្រាប់អនុវត្តតែទៅលើនាយទាហាននិងអ្នករដ្ឋការជាន់ខ្ពស់តែប៉ុណ្ណោះ។ ប៉ុន្តែនៅដើមឆ្នាំ១៩៧៦ នយោបាយនេះបានពង្រីកដោយរួមបញ្ចូលទាំងមន្ត្រីដែលគ្មានឋានន្តរសក្តិ ទាហានធម្មតា និងអ្នករដ្ឋការតូចតាច។<br>**#១២ ក** | ការសម្លាប់រង្គាលដោយមិនរើសមុខ ទៅលើនាយទាហាន ពលទាហាននិងអ្នករដ្ឋការរបស់របបមុន ព្រមទាំងគ្រួសាររបស់គេ។<br>**#I.១** |
| បក្សកុម្មុយនីស្តកម្ពុជា មានមាគ៌ានយោបាយជាក់លាក់មួយក្នុងការលុបបំបាត់ចោល “ពួកសក្តិភូមិ” “ពួកនាយទុន” និង “ពួកគហបតី”។ បក្សបានធ្វើការប្រកាសថាដោយសារតែប្រភពនៃវណ្ណៈរបស់ខ្លួន ពួកសក្តិភូមិនិងនាយទុនមិនអាចធ្វើការកសាងខ្លួនបានទេ ហើយបានធ្វើការអះអាងថា ខ្មាំងស៊ីរូងផ្ទៃក្នុងនឹងមិនអាចបញ្ឈប់បានទេ ដរាបណា វណ្ណៈប្រតិកិរិយាទាំងនេះ នៅមិនទាន់បានលុបបំបាត់ទាំងស្រុងនោះ។ | សម្លាប់រង្គាលបញ្ញវ័ន្ត<br>**#I.២** |

| #១២ ខ | |
|---|---|
| បក្សកុម្មុយនីស្តកម្ពុជា បានធ្វើការបែងចែករវាងប្រជាជន “ថ្មី” និងប្រជាជន “ចាស់” ឬប្រជាជន “ មូលដ្ឋាន” ។ ប្រជាជន “ថ្មី” គឺអ្នកដែលបានជម្លៀសចេញពីទីក្រុង ឬផ្នែកដទៃទៀតនៃប្រទេស ដែលកាលពីមុនមក ស្ថិតនៅក្រោមការត្រួតត្រារបស់រដ្ឋាភិបាលសាធារណរដ្ឋខ្មែរ។ ប្រជាជន “ចាស់” ឬប្រជាជន “មូលដ្ឋាន” គឺប្រជាជនដែលបានរស់នៅក្នុងតំបន់ត្រួតត្រាដោយបក្សកុម្មុយនីស្តកម្ពុជា ក្នុងអំឡុងពេលសាធារណរដ្ឋខ្មែរ។ យោងតាមបក្សកុម្មុយនីស្តកម្ពុជា ទោះបីជា “ប្រជាជនថ្មី” ទាំងនោះ មិនស្ថិតនៅក្នុងក្រុមដែលជាគោលដៅក្តី ក៏មានឆ្លងនូវ “អាកប្បកិរិយារបស់ពួកចក្រពត្តិ ពួកសក្តិភូមិ និងពួកនាយទុនដែរ” ហើយបក្សកុម្មុយនីស្តកម្ពុជាបានជំរុញយ៉ាងសកម្មនូវគំនិតដែលថា ប្រជាជនចាស់ ឬប្រជាជនមូលដ្ឋាន គឺប្រសើរជាងប្រជាជនថ្មី ។<br>**#១២ គ** | ពួកប៉ុលពត - អៀងសារី បានបែងចែកប្រជាជនកម្ពុជាចេញជាបីប្រភេទក្នុងការគ្រប់គ្រងរបស់គេ។ ប្រភេទទី ១ គឺប្រជាជនចាស់ដែលរស់នៅមូលដ្ឋានមុនថ្ងៃរំដោះ។ ប្រភេទទី ២ គឺជាប្រជាជនថ្មីដែលរស់នៅកន្លែងដែលរបបមុនកាន់កាប់។ ប្រភេទទី ៣ គឺប្រជាជនដែលបានធ្វើសហប្រតិបត្តិការជាមួយរបបមុន។ ពួកគេមានផែនការកំទេចប្រជាជនប្រភេទទី៣ ចម្រាញ់ប្រភេទទី ២ ឯប្រជាជនប្រភេទទី ១ មុនដំបូងត្រូវបានទំនុកបំរុងយ៉ាងសមរម្យ ក៏ប៉ុន្តែចាប់តាំងពីឆ្នាំ ១៩៧៧ មកក៏ត្រូវពួកគេចម្រាញ់ដែរ។<br>**#I** |
| ពុទ្ធសាសនិកជនត្រូវបានគេរើសអើងយ៉ាងទូលំទូលាយ ដែលជាផ្នែកមួយនៃគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការលុបបំបាត់សាសនា។ បក្សកុម្មុយនីស្តកម្ពុជាបានហាមប្រាមការគោរពព្រះពុទ្ធសាសនា បានផ្សឹកព្រះសង្ឃទាំងអស់ និងបានធ្វើគត់ព្រះសង្ឃពុទ្ធសាសនាជាច្រើនអង្គ និងបានធ្វើឱ្យខូចខាតឬបំផ្លិចបំផ្លាញវត្តជាច្រើនទៀត។<br>**#១២ ឃ** | ការសម្លាប់រង្គាលមេដឹកនាំសាសនា សាសនិកជន ការលុបបំបាត់សាសនា។<br>**#II**<br>ការបាញ់កាំភ្លើងចូលទៅក្នុងអាគារសាសនា បង្ខំអោយអ្នកបួសចាកសិក្ខាបទ ព្រះបដិមាករត្រូវវាយបំបែកចោលអស់ វត្តអារាមត្រូវក្លាយទៅជាទីឃុំឃាំង ឬជំរុំប្រមូលផ្តុំ ឬឃ្លាំងស្តុក។<br>**#II** |
| បក្សកុម្មុយនីស្តកម្ពុជា បានសម្លាប់សមាជិកជនជាតិភាគតិចចាមនិងអ្នកកាន់សាសនាអ៊ីស្លាមជាច្រើននាក់ | ការសម្លាប់រង្គាលអ្នកដឹកនាំសាសនា សាសនិកជន ការលុបបំបាត់សាសនា។ |

| | |
|---|---|
| ដែលជាផ្នែកមួយនៃនយោបាយក្នុងការរុករកដើម្បីលុបបំបាត់ចោលវប្បធម៌ចាម និង ការប្រតិបត្តិសាសនាអ៊ីស្លាម។ ពួកគេបានធ្វើការបង្ខំបំបែកប្រជាជនចាមឱ្យទៅរស់នៅពាសពេញប្រទេស ហាមពួកគេមិនឱ្យចូលរួមក្នុងសកម្មភាពឬពិធីបុណ្យសាសនាអ៊ីស្លាម និងហាមមិនឱ្យពួកគេមានអត្ថបទសាសនាអ៊ីស្លាមជាកម្មសិទ្ធិ។ បក្សកុម្មុយនីស្តកម្ពុជាបានកំណត់គោលដៅយកទៅប្រហារជីវិត រាល់អ្នកដឹកនាំនយោបាយនិងសាសនាអ៊ីស្លាម ព្រមទាំងជនជាតិចាមទាំងឡាយដែលបដិសេធមិនព្រមបោះបង់សាសនារបស់ខ្លួន។ នៅក្នុងអំឡុងពេលនៃដំណើរការនេះ វិហារជាច្រើនត្រូវបានធ្វើឱ្យខូចខាតឬបំផ្លិចបំផ្លាញចោល។<br>**#១២ ង** | **#II**<br>ការបាញ់កាំភ្លើងចូលទៅក្នុងអាគារសាសនាបង្ខំឲ្យអ្នកបួសចាកសិក្ខាបទ ព្រះបដិមាករត្រូវវាយបំបែកចោលអស់។<br>**#II**<br>ការដាក់ឲ្យរស់នៅលាយឡំដោយបង្ខំ និងការសម្លាប់រង្គាល...កម្មាភិបាលជនជាតិភាគតិចទាំងអស់ត្រូវសម្លាប់។<br>**#II** |
| បក្សកុម្មុយនីស្តកម្ពុជាបានបន្តធ្វើនយោបាយរើសអើងនិងសម្លាប់ជនជាតិភាគតិចវៀតណាម។ ពីដំបូង បក្សកុម្មុយនីស្តកម្ពុជាបានអនុម័តនូវនយោបាយមួយក្នុងការបោសសំអាតជនទាំងឡាយដែលត្រូវបានគេចាត់ទុកថាជាជនជាតិវៀតណាម ឬអ្នកដែលជាប់ទាក់ទងជាមួយប្រទេសវៀតណាម។ យ៉ាងណាមិញ ទំនាក់ទំនងរវាងបក្សកុម្មុយនីស្តកម្ពុជាជាមួយប្រទេសវៀតណាម បានចុះដុនដាបជាលំដាប់ ហើយមានទស្សនៈដែលចេះតែកើនឡើងថា ប្រទេសវៀតណាមគឺជាខ្មាំង។ ទស្សនៈនេះវាស៊ីគ្នាទៅនឹងជំនឿដែលថាគិញវៀតណាម កំពុងព្យាយាមរំលំបក្សកុម្មុយនីស្តកម្ពុជា។ មកដល់ពាក់កណ្តាលនិងចុងឆ្នាំ ១៩៧៧ គោលនយោបាយបានវិវត្តន៍ទៅជាគោលនយោបាយមួយដែលលុបបំបាត់ប្រជាជនទាំងអស់ដែលមានទំនាក់ទំនងជាមួយ | ការដាក់ឲ្យរស់នៅលាយឡំដោយបង្ខំ និងការសម្លាប់រង្គាល...កម្មាភិបាលជនជាតិភាគតិចទាំងអស់ត្រូវសម្លាប់ អាណិកជនចិន ឬវៀតណាមត្រូវបានសម្លាប់។<br>**#II** |

| | |
|---|---|
| ប្រទេសវៀតណាម។<br>**#១២ ច** | |
| បក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តការបោសសំអាតម្តងហើយម្តងទៀត ដែលតាមរយៈការបោសសំអាតនោះ កម្មាភិបាលនិងបុគ្គលិកដទៃទៀតបំរើការឱ្យបក្សកុម្មុយនីស្តកម្ពុជា ត្រូវបានដកហូតពីមុខតំណែងសិទ្ធិអំណាច ហើយជាញឹកញាប់ត្រូវបានគេសម្លាប់ចោល (“កំទេច”) ដោយសារតែមានការប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជាពិតប្រាកដឬតាមតែគេគិតថាមាន។ កម្មាភិបាលដឹកនាំ បុគ្គលិកសន្តិសុខ និង ប្រជាជនគ្រប់ស្រទាប់ទាំងអស់នៅក្នុងសង្គម ស្ថិតនៅក្រោមការណែនាំថា ត្រូវមានការប្រុងប្រយ័ត្នជាប្រចាំ ប្រឆាំងនឹងខ្មាំង “ស៊ីរូងផ្ទៃក្នុង” និង “ធ្វើការវាយប្រហារនិងបោសសំអាតជាបន្តបន្ទាប់មកលើសមាសភាពមិនល្អ”។<br>**#១២ ឆ** | ការបង្ក្រាបដែលមានលក្ខណៈធ្ងន់ធ្ងរ និងការសម្លាប់រង្គាលជាលក្ខណៈប្រព័ន្ធលើបុគ្គលនិងអង្គការដែលសង្ស័យថាប្រឆាំងនឹងរបបនេះ។<br>**#I.៣** |
| មិនមានពេលណាមួយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលមានប្រព័ន្ធតុលាការដែលដំណើរការ ឬយន្តការច្បាប់ដទៃទៀត ដែលតាមរយៈប្រព័ន្ធឬយន្តការទាំងនោះ អ្នកដែលត្រូវបានគេចាប់ឬឃុំខ្លួន អាចទទួលបាននូវការកាត់សេចក្តីដោយយុត្តិធម៌នោះទេ។ ជំនួសឱ្យប្រព័ន្ធនោះ បក្សកុម្មុយនីស្តកម្ពុជាបានបង្កើតនូវប្រព័ន្ធឋានានុក្រមមួយ នៃមណ្ឌលលត់ដំនិងសន្តិសុខនៅទូទាំងរបបកម្ពុជាប្រជាធិបតេយ្យដែលប្រតិបត្តិការនៅក្រោមការត្រួតពិនិត្យនិងការណែនាំរបស់កម្ពុជាប្រជាធិបតេយ្យ និងរាយការណ៍ព្រមទាំងតាមដានដោយរដ្ឋអំណាចឃោឌានិងស៊ីវិលថ្នាក់ខ្ពស់បំផុត។ មណ្ឌលអស់ទាំងនេះដំណើរការជាមន្ទីរឃុំឃាំង មន្ទីរសួរចម្លើយ | ក្នុងរយៈពេល៤ឆ្នាំដែលពួកគេកាន់អំណាច បនប៉ុល ពត អៀង សារី បានប្រើវិធីធ្វើទារុណកម្ម និងសម្លាប់មនុស្សយ៉ាងព្រៃផ្សៃបំផុត។<br>**#VIII** |

| | |
|---|---|
| និងធ្វើទារុណកម្ម កន្លែងកសាងខ្លួន និងជាទីកន្លែងប្រហារជីវិតសម្រាប់អ្នកទាំងឡាយដែលត្រូវបានគេចាត់ទុកថាជាខ្មាំង ឬជាអ្នកប្រឆាំងនឹងរបបនោះ។<br>**#១៣** | |
| ការជម្លៀសប្រជាជនចេញពីតំបន់ទីក្រុង ទិសដៅផលិតផលហួសប្រមាណ និងការបដិសេធមិនព្រមទទួលយកជំនួយនិងយន្តកម្មអន្តរជាតិ ធ្វើឱ្យប្រជាជនមានស្ថានភាពរស់នៅអមនុស្សធម៌នៅតាមសហករណ៍ ដោយសារតែប្រជាជនត្រូវបានបង្ខំឱ្យធ្វើការងារពលកម្ម ខណៈពេលដែលប្រជាជនទទួលចំណីអាហារមិនគ្រប់គ្រាន់ និងការថែទាំសុខភាពមិនគ្រប់គ្រាន់នោះទេ។ ស្ថានភាពអមនុស្សធម៌ក៏បានកើតមានឡើងនៅតាមការដ្ឋានរដ្ឋាភិបាលជាច្រើនដែរ។ ជនសង្ស័យបានដឹងពីស្ថានភាពអមនុស្សធម៌ទាំងនេះ ក៏ប៉ុន្តែទោះបីជាបានដឹងដូច្នោះក្តី ពួកគេបានបង្ខំឱ្យប្រតិបត្តិតាមគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា តាមរយៈការឃ្លាំមើលប្រជាជន ការដាក់ទណ្ឌកម្មឬសម្លាប់អ្នកដែលបានប្រព្រឹត្តអំពើខុសឆ្គងសូម្បីតែតិចតួចក៏ដោយ។<br>**#១៤** | ការបណ្តេញប្រជាជនចេញពីក្រុងភ្នំពេញ ពីទីប្រជុំជន និងជនបទដែលរំដោះបាន ការបំបែកនិងបង្កការឈឺចាប់ដល់ក្រុមគ្រួសារនិងរចនាសម្ព័ន្ធសង្គម ការសម្លាប់រង្គាល និងការបង្កើតស្ថានភាពគ្រោះថ្នាក់ដល់ជីវិត។<br>**#III**<br>ការបង្ខំប្រជាជនឱ្យចូល“សហករណ៍” ដែលជាជំរុំប្រមូលផ្តុំក្លែងក្លាយ ដែលប្រជាជនត្រូវបានបង្ខំឱ្យធ្វើការនិងរស់ក្នុងលក្ខណៈវិនាសអន្តរាយលើរូបរាងកាយនិងស្មារតី សម្លាប់រង្គាល ឬបានស្លាប់មួយចំនួនធំ។ (**ផ្នែករូបរាងកាយ៖** ការធ្វើពលកម្មធ្ងន់ របបហូបមិនគ្រប់គ្រាន់ គ្មានថ្នាំព្យាបាល ស្ត្រីភាគច្រើនមិនអាចមានកូន) (**ផ្នែកស្មារតី៖** កុមារអាយុលើសពី៦ឆ្នាំ ត្រូវបំបែកចេញឱ្យរស់នៅដោយឡែកឆ្ងាយពីឪពុកម្តាយ កុមារត្រូវអប់រំឱ្យស្មោះត្រង់តែជាមួយអង្គការ ស្នេហាត្រូវបានហាមឃាត់យ៉ាងតឹងរឹង អាពាហ៍ពិពាហ៍ត្រូវសម្រេចដោយអង្គការ ការបង្ខំឱ្យស្ត្រីមេម៉ាយព្រមទទួលយកទាហានដែលពិការជាប្តី លុបបំបាត់ចោលមធ្យោបាយផ្សព្វផ្សាយពត៌មាន គមនាគន៍ប្រាក់កាស និងពាណិជ្ជកម្ម ភ្នាក់ងារចារកម្មឈ្លបយកការណ៍ទាំងយប់ទាំងថ្ងៃ)។<br>**#IV** |

| | |
|---|---|
| ការធ្វើទារុណកម្ម និងការរំលោភលើរូបកាយជាទូទៅ នៅតាមមណ្ឌលសន្តិសុខ នៅតាមសហករណ៍និងការដ្ឋាន ដើម្បីស្រង់យក "ចម្លើយសារភាព" នៃ "បទល្មើស" ដែលត្រូវបានគេចោទប្រកាន់ និងដើម្បីបង្ខំការគោរពវិន័យ។ "ចម្លើយសារភាព" ត្រូវបានផ្សព្វផ្សាយក្នុងចំណោមមេដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា និងសហចារីនៃសហកម្មឧក្រិដ្ឋកម្មរួម ដូចជា **នួន ជា, អៀង សារី, ខៀវ សំផន** និង **អៀង ធីរិទ្ធ**។ ចម្លើយសារភាពត្រូវបានបក្សកុម្មុយនីស្តកម្ពុជាប្រើជាឧបករណ៍ឃោសនា ដើម្បីបង្ហាញពីហេតុផលនៃការចាប់ខ្លួន និងការប្រហារជីវិតជនរងគ្រោះ ដែលបានផ្តល់ "ចម្លើយសារភាព" និងដើម្បីទទួលយកឈ្មោះអ្នកដទៃទៀត ដែលក្រោយមកអ្នកទាំងនោះត្រូវបានចាប់ខ្លួន ធ្វើទារុណកម្ម និងផ្តល់ "ចម្លើយសារភាព" ហើយត្រូវបានគេប្រហារជីវិត។ ទង្វើនេះបានធ្វើឲ្យកើតនូវការសម្លាប់ជាបន្តបន្ទាប់។<br>**#១៥** | ក្នុងរយៈពេល៤ឆ្នាំដែលពួកគេកាន់អំណាច បនប៉ុល ពត អៀង សារី បានប្រើវិធីធ្វើទារុណកម្ម និងសម្លាប់មនុស្សយ៉ាងព្រៃផ្សៃបំផុត។<br>**#VIII** |
| សកម្មភាពរបស់ពួកគេបានបណ្តាលឱ្យប្រជាជនស្លាប់ចំនួន ពី ១,៧ លាន ទៅ ២,២ លាន នាក់ ក្នុងចំណោមប្រជាជនប្រហែល ៧លាន នាក់ ដោយសារតែការធ្វើការបាក់កម្លាំង ភាពអត់ឃ្លាន ជំងឺ ឬការប្រហារជីវិត ។ ទោះបីជាអ្នកដែលមិនត្រូវបានសម្លាប់ក្តី ក៏អ្នកទាំងនោះ ជាជនរងគ្រោះនៃគោលនយោបាយឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយពួកគេទទួលរងការធ្វើទារុណកម្ម ការធ្វើការដោយបង្ខំ ការឃុំខ្លួនខុសច្បាប់ ការធ្វើទុក្ខបុកម្នេញផ្នែកសាសនា ការផ្លាស់ប្តូរទីកន្លែងដោយបង្ខំ និងប្រព្រឹត្តកម្មអមនុស្សធម៌ដទៃទៀត។ | ទាំងអស់ |

| | |
|---|---|
| **#១៦** | |
| គណៈកម្មាធិការអចិន្ត្រៃយ៍បានពិភាក្សានិងបញ្ជានូវការជម្លៀសដោយបង្ខំទ្រង់ទ្រាយធំ បានពិភាក្សានិងបញ្ជាការប្រើឲ្យធ្វើពលកម្មដោយបង្ខំ បានបញ្ជាឲ្យចាប់ខ្លួននិងសួរចម្លើយ "ខ្មាំង" បានដឹងពីស្ថានភាពរស់នៅអមនុស្សធម៌នៅទូទាំងប្រទេស និងមានសិទ្ធិអំណាចបញ្ជាឲ្យប្រហារជីវិតប្រជាជនតាមទំនើងចិត្ត។<br>**#២៥** | ក្នុងរយៈពេល៤ឆ្នាំដែលពួកគេកាន់អំណាច បនប៉ុល ពត អៀង សារី បានប្រើវិធីធ្វើទារុណកម្ម និងសម្លាប់មនុស្សយ៉ាងព្រៃផ្សៃបំផុត។<br>**#VIII** |
| យ៉ាងណាមិញ រចនាសម្ព័ន្ធភូមិរបៀបបុរាណរបស់ខ្មែរត្រូវបានលុបបំបាត់ជាបណ្តើរៗ ហើយប្រជាជនត្រូវបានបង្ខំឱ្យចូលរួមក្នុង "សហករណ៍"។<br>**#២៩** | ការបង្ខំប្រជាជនឲ្យចូល"សហករណ៍" ដែលជាជំរុំប្រមូលផ្តុំក្លែងក្លាយ ដែលប្រជាជនត្រូវបានបង្ខំឲ្យធ្វើការនិងរស់ក្នុងលក្ខណៈវិនាសអន្តរាយលើរូបរាងកាយនិងស្មារតី សម្លាប់រង្គាល ឬបានស្លាប់មួយចំនួនធំ។<br>**#IV** |
| **ឧក្រិដ្ឋកម្ម** | |
| **ការជម្លៀសដោយបង្ខំ** | |
| **ការជម្លៀសដោយបង្ខំពីភ្នំពេញ - ដំណាក់កាលទី ១** | |
| ចាប់ពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ មន្ត្រីបក្សកុម្មុយនីស្តកម្ពុជា បានបង្ខំជម្លៀស ប្រជាជននៅភ្នំពេញទាំងអស់ចំនួនប្រមាណ ២ លាននាក់ ឱ្យទៅជនបទ។ ប្រជាជនទាំងនេះ ត្រូវបានណែនាំថាមិនបាច់យកឥវ៉ាន់ទៅច្រើនពេកទេ ហើយបក្សកុម្មុយនីស្តកម្ពុជាបានដកហូតយកកម្មសិទ្ធិឯកជនទាំងអស់។ ប្រជាជនជាច្រើននាក់ត្រូវបានបង្ខំឱ្យធ្វើដំណើរយ៉ាងឆ្ងាយ ពេលខ្លះដោយដើរ ឬដឹកតាមឡាន ដែលញាត់មនុស្សណែនៗ មុនដាក់ | ការបណ្តេញប្រជាជនចេញពីក្រុងភ្នំពេញ ពីទីប្រជុំជន និងជនបទដែលរំដោះបាន ការបំបែកនិងបង្កការឈឺចាប់ដល់ក្រុមគ្រួសារនិងរចនាសម្ព័ន្ធសង្គម ការសម្លាប់រង្គាល និងការបង្កើតស្ថានភាពគ្រោះថ្នាក់ដល់ជីវិត។<br>**#III** |

| | |
|---|---|
| ឱ្យរស់នៅដោយខុសច្បាប់ក្នុងសហករណ៍ជនបទ។<br>**#៣៧** | |
| ការជម្លៀសប្រជាជនដោយបង្ខំចេញពីភ្នំពេញ បានបណ្តាលឱ្យស្លាប់ជាច្រើននាក់: ប្រជាជនត្រូវបានសម្លាប់ដោយសារមិនព្រមចាកចេញពីផ្ទះរបស់ពួកគេ ទាហានបក្សកុម្មុយនីស្តកម្ពុជា បានស្វែងរកនិងសម្លាប់អតីតមន្ត្រីរាជការ និងនាយទាហានសាធារណរដ្ឋខ្មែរ ហើយមនុស្សរាប់ពាន់នាក់បានស្លាប់ ដោយកង្វះម្ហូបអាហារ ទឹក ទីជម្រក និងការខ្វះជំនួយផ្នែកពេទ្យ។<br>**#៣៨** | ការសម្លាប់បំផុតពូជដោយមិនរើសមុខទៅលើនាយទាហាន ពលទាហាននិងអ្នករដ្ឋការរបស់របបមុន ព្រមទាំងគ្រួសាររបស់គេ។<br>**#I.២**<br>ការបណ្តេញប្រជាជនចេញពីក្រុងភ្នំពេញ ពីទីប្រជុំជន និងជនបទដែលរំដោះបាន ការបំបែកនិងបង្កការឈឺចាប់ដល់ក្រុមគ្រួសារនិងរចនាសម្ព័ន្ធសង្គម ការសម្លាប់រង្គាល និងការបង្កើតស្ថានភាពគ្រោះថ្នាក់ដល់ជីវិត។<br>**#III** |
| **ការជម្លៀសដោយបង្ខំទៅភូមិភាគឧត្តរ និងពាយ័ព្យ – ដំណាក់កាលទី ២** | |
| ចាប់ពីចុងឆ្នាំ ១៩៧៥ និងបន្តរហូតដល់ដើមឆ្នាំ ១៩៧៦ បក្សកុម្មុយនីស្តកម្ពុជា បានបញ្ជាឱ្យជម្លៀសប្រជាជនដោយបង្ខំក្នុងដំណាក់កាលទីពីរដោយទ្រង់ទ្រាយធំ ដែលបានបណ្តាលឱ្យប្រជាជនរាប់រយពាន់នាក់ត្រូវផ្លាស់ប្តូរទីកន្លែងដោយបង្ខំ ពីផ្នែកកណ្តាលនិងផ្នែកនិរតីនៃប្រទេស ក្នុងនោះរួមមានពីឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម ឃុំព្រះផ្លូស ស្រុកកោះសូទិន ខេត្តកំពង់ចាម ឃុំព្រះផ្លូស ស្រុកកោះសូទិន ខេត្តកំពង់ចាម និងឃុំកោះអណ្តែត ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ទៅភូមិភាគឧត្តរនិងពាយ័ព្យ។ មានការប៉ាន់ប្រមាណថាមានមនុស្សរាប់សិបពាន់នាក់បានស្លាប់ ដោយសារការហូបមិនគ្រប់គ្រាន់ មានជម្ងឺ ការប្រហារជីវិត និងការធ្វើការហួស | ការបណ្តេញប្រជាជនចេញពីក្រុងភ្នំពេញ ពីទីប្រជុំជន និងជនបទដែលរំដោះបាន ការបំបែកនិងបង្កការឈឺចាប់ដល់ក្រុមគ្រួសារនិងរចនាសម្ព័ន្ធសង្គម ការសម្លាប់រង្គាល និងការបង្កើតស្ថានភាពគ្រោះថ្នាក់ដល់ជីវិត។<br>**#III** |

| | |
|---|---|
| កម្លាំង។<br>**#៤០** | |
| ក្នុងចំណោមមនុស្សដែលត្រូវបានឱ្យផ្លាស់ទីកន្លែងដោយបង្ខំនេះ គឺមានសមាជិកនៃជនជាតិភាគតិចចាមនិងអ្នកកាន់សាសនាអ៊ីស្លាម។ នៅឆ្នាំ ១៩៧៥ ប្រជាជនចាមនៅកម្ពុជាប្រជាធិបតេយ្យ ប្រមូលផ្តុំរស់នៅក្នុងខេត្តកំពង់ចាម កំពង់ឆ្នាំង និងពោធិ៍សាត់។ ចាប់ពីចុងឆ្នាំ ១៩៧៥ មក បក្សកុម្មុយនីស្តកម្ពុជា បានធ្វើការជម្លៀសដោយបង្ខំប្រជាជនចាមពីភូមិរបស់ពួកគេ ហើយបំបែកពួកគេដោយបង្ខំឱ្យទៅរស់នៅច្របូកច្របល់ក្នុងភូមិខ្មែរ។ ចាមរាប់សិបពាន់នាក់ ត្រូវបានផ្លាស់ប្តូរទីកន្លែងដោយបង្ខំ ឱ្យទៅនៅភូមិភាគឧត្តរ និងពាយ័ព្យ ជាផ្នែកមួយនៃនយោបាយជាក់លាក់មួយដើម្បី “បំបែកពួកចាមចេញពីគ្នា”។ ការនេះបានកើតមាននៅក្នុងមូលដ្ឋានមួយចំនួន រួមមានឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម និងឃុំកោះធំ ស្រុកកោះធំ ខេត្តកណ្តាល។ ការជម្លៀសដោយបង្ខំនេះ និងការរើសអើងជាប្រព័ន្ធ ដែលបានកើតមានឡើងនៅពេលក្រោយមក បណ្តាលឱ្យចាមជាច្រើននាក់ស្លាប់។<br>**#៤១** | ការលុបបំបាត់សាសនា ការសម្លាប់រង្គាលជនជាតិភាគតិច ការដាក់ឲ្យជនជាតិភាគតិចរស់នៅលាយឡំដោយបង្ខំ។<br>**#II** |
| **ការជម្លៀសប្រជាជនដោយបង្ខំចេញពីភូមិភាគបូព៌ា – ដំណាក់កាលទី ៣** | |
| នៅពាក់កណ្តាលឆ្នាំ ១៩៧៨ ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បានបញ្ជាការជម្លៀសដោយបង្ខំជាទ្រង់ទ្រាយធំជាលើកទី៣ ដែលបានបណ្តាលឱ្យមនុស្សរាប់សិបពាន់នាក់ រស់នៅភូមិភាគបូព៌ា ត្រូវបានបង្ខំឱ្យទៅតាំងទីលំនៅជាថ្មីនៅភូមិភាគកណ្តាល បស្ចិម និងពាយ័ព្យ។ | ការបណ្តេញប្រជាជនចេញពីក្រុងភ្នំពេញ ពីទីប្រជុំជន និងជនបទដែលរំដោះបាន ការបំបែកនិងបង្កការឈឺចាប់ដល់ក្រុមគ្រួសារនិងរចនាសម្ព័ន្ធសង្គម ការសម្លាប់រង្គាល និងការបង្កើតស្ថានភាពគ្រោះថ្នាក់ដល់ជីវិត។ |

| | |
|---|---|
| មនុស្សទាំងនេះ រួមមានអ្នកមកពីឃុំអង្គការ និង ឃុំស្វាយជ្រុំ ស្រុកមេសាង ខេត្តព្រៃវែង និងឃុំអំពិល ឃុំសំបួរ ឃុំរមាសហែក ស្រុករមាសហែក ខេត្តស្វាយរៀង។ ការជម្លៀសដោយបង្ខំនេះ បានកើតមានឡើងនៅក្នុងពេលបោសសំអាតមេដឹកនាំភូមិភាគបូព៌ា និងធ្វើយ៉ាងណាដើម្បីបំបែកប្រជាជនចេញពីគ្នា និងចេញពីក្រុមដែលបក្សកុម្មុយនីស្តកម្ពុជា កំណត់ថាអាចជាពួកមិនស្មោះត្រង់។ ប្រជាជនជាច្រើននាក់ត្រូវសម្លាប់ដោយចេតនា ឬស្លាប់ដោយបណ្តាលមកពីការជម្លៀសដោយបង្ខំ។<br>#៤២ | #III<br><br>ការបង្ក្រាបដែលមានលក្ខណៈធ្ងន់ធ្ងរ និងការសម្លាប់រង្គាលជាលក្ខណៈប្រព័ន្ធលើបុគ្គលនិងអង្គការដែលសង្ស័យថាប្រឆាំងនឹងរបបនេះ (បោសសម្អាតអង្គការខ្លួនឯងនិងសម្លាប់ជនណាដែលសង្ស័យថាក្បត់ពួកគេ)។<br>#I.៣ |
| **ការធ្វើពលកម្មដោយបង្ខំ ស្ថានភាពរស់នៅអមនុស្សធម៌ និងការឃុំឃាំងខ្លួនដោយខុសច្បាប់** | |
| **ភូមិភាគនិរតី - សហករណ៍នៅក្នុងស្រុកត្រាំកក់** | |
| មានការឃុំខ្លួនដោយខុសច្បាប់ ការបង្ខំឱ្យធ្វើពលកម្មដោយបង្ខំ ការផ្តល់ម្ហូបអាហារមិនគ្រប់គ្រាន់ ទុក្ខវេទនាធ្ងន់ធ្ងរ និងការចាប់ចងតាមទំនើងចិត្ត នៅក្នុងសហករណ៍នៅក្នុងឃុំគូស ឃុំសំរោង ឃុំត្រពាំងធំត្បូង ឃុំត្រពាំងធំជើង ឃុំត្រាំកក់ ឃុំញ៉ែងញ៉ង ឃុំស្រែរណុង និង ឃុំតាផែន ស្រុកត្រាំកក់ ខេត្តតាកែវ នៃភូមិភាគនិរតី។<br><br>ប្រជាជនរាប់ពាន់នាក់អត់បាយរហូតដល់ស្លាប់ នៅក្នុងសហករណ៍ទាំងនេះ និងត្រូវបានកប់ដោយរាយប៉ាយក្នុងព្រៃ។ មន្ត្រីនៃរបបកម្ពុជាប្រជាធិបតេយ្យ បានរឹបអូសយកស្រូវទុក ទោះបីជាអាជ្ញាធរស្រុកបានដឹងថា | ការបង្ខំប្រជាជនឲ្យចូល"សហករណ៍" ដែលជាជំរុំប្រមូលផ្តុំក្លែងក្លាយ ដែលប្រជាជនត្រូវបានបង្ខំឲ្យធ្វើការនិងរស់ក្នុងលក្ខណៈវិនាសអន្តរាយលើរូបរាងកាយនិងស្មារតី សម្លាប់រង្គាល ឬបានស្លាប់មួយចំនួនធំ។ (**ផ្នែករូបរាងកាយ៖** ការធ្វើពលកម្មធ្ងន់ របបហូបមិនគ្រប់គ្រាន់ គ្មានថ្នាំព្យាបាល ស្ត្រីភាគច្រើនមិនអាចមានកូន) (**ផ្នែកស្មារតី៖** កុមារអាយុលើសពី៦ឆ្នាំ ត្រូវបំបែកចេញឲ្យរស់នៅដោយឡែកឆ្ងាយពីឪពុកម្តាយ កុមារត្រូវអប់រំឲ្យស្មោះត្រង់តែជាមួយអង្គការ ស្នេហាត្រូវបាន |

| | |
|---|---|
| ប្រជាជនរាប់ពាន់នាក់មានការអត់បាយរហូតដល់ស្លាប់ក៏ដោយ។<br><br>អ្នកណាប៉ានត្អូញត្អែរអំពីស្ថានភាពរស់នៅនៅក្នុងឃុំទាំងនេះ ត្រូវបានចោទថាជាខ្មាំង និងត្រូវចាប់ខ្លួន។ អតីតមន្ត្រី និងទាហានសាធារណរដ្ឋខ្មែរ ត្រូវទទួលរងការរើសអើង តាមដាន ចាប់ខ្លួន និង ប្រហារជីវិត។<br><br>លើសពីនេះទៅទៀត "ប្រជាជនថ្មី" ជាច្រើននាក់ ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរឃុំឃាំង ស្ថិតនៅក្រាំងតាចាន់ ស្រុកត្រាំកក់ ដែលពួកគេត្រូវសម្លាប់នៅទីនោះ។<br>**#៤៣** | ហាមឃាត់យ៉ាងតឹងរឹង អាពាហ៍ពិពាហ៍ត្រូវសម្រេចដោយអង្គការ ការបង្ខំឲ្យស្ត្រីមេម៉ាយព្រមទទួលយកទាហានដែលពិការជាប្តី លុបបំបាត់ចោលមធ្យោបាយផ្សព្វផ្សាយពត៌មាន គមនាគន៍ ប្រាក់កាស និងពាណិជ្ជកម្ម ភ្នាក់ងារចារកម្មឈ្លបយកការណ៍ទាំងយប់ទាំងថ្ងៃ)។<br>**#IV** |
| **ភូមិភាគបស្ចឹម - ការដ្ឋានស្រែអំបិលរបស់រដ្ឋាភិបាល** | |
| ប្រជាជនរាប់ពាន់នាក់ ភាគច្រើនជាស្ត្រី ត្រូវបានឃុំឃាំងដោយខុសច្បាប់ និងបង្ខំឱ្យធ្វើការដោយកម្លាំងកាយយ៉ាងខ្លាំង ដោយឱ្យបរិភោគនិងផ្តល់ការថែរក្សាសុខភាពមិនគ្រប់គ្រាន់ នៅការដ្ឋានផលិតកម្មអំបិលឈ្មោះស្រែអំបិលស្ថិតនៅកន្លែងជុំវិញភូមិស្រែអំបិល ឃុំស្រែអំបិល ស្រុកកំពត ខេត្តកំពត។ កម្មករធ្វើការជាប្រចាំ ដើម្បីផលិតអំបិលឱ្យបានច្រើន និងដឹកជញ្ជូនចេញ ស្របតាមកំរិតផលិតផលដែលបក្សកុម្មុយនីស្តកម្ពុជាតម្រូវឱ្យធ្វើ។ ទោះបីឈឺក៏ដោយក៏ត្រូវតែធ្វើការដែរ ហើយពួកមិនអាចធ្វើការបាន ត្រូវទទួលរងការវាយដំ បង្អត់អាហារ ឬសម្លាប់។<br>**#៤៤** | ក្នុងរយៈពេល៤ឆ្នាំដែលពួកគេកាន់អំណាច បនប៉ុល ពត អៀង សារី បានប្រើវិធីធ្វើទារុណកម្ម និងសម្លាប់មនុស្សយ៉ាងព្រៃផ្សៃបំផុត។<br>**#VIII** |
| **ភូមិភាគកណ្តាល (អតីតភូមិភាគឧត្តរ) - ទំនប់ ១ មករា** | |

| | |
|---|---|
| កម្មកររាប់សិបពាន់នាក់ មកពីតំបន់ ៤១ ៤២ និង ៤៣ ត្រូវបានបង្ខំឱ្យមកធ្វើការនៅក្នុងផែនការកសាងទំនប់នេះ។ ស្ថានភាពធ្វើការនិងរស់នៅ នៅការដ្ឋាននេះគឺអមនុស្សធម៌ ហើយអ្វីដែលជាបច្ច័យផ្ទាល់គឺបានបណ្តាលឱ្យមនុស្សប្រមាណ ២០ ០០០នាក់ ស្លាប់ដោយការអត់ឃ្លាន ការធ្វើការហួសកម្លាំង ឬការសម្លាប់។ **#៤៥** | ក្នុងរយៈពេល៤ឆ្នាំដែលពួកគេកាន់អំណាច បនប៉ុល ពត អៀង សារី បានប្រើវិធីធ្វើទារុណកម្ម និងសម្លាប់មនុស្សយ៉ាងព្រៃផ្សៃបំផុត។ **#VIII** |
| **ភូមិភាគពាយ័ព្យ - ត្រពាំងថ្ម** | |
| ប្រជាជនរាប់ពាន់នាក់ត្រូវទទួលរងនូវការបង្ខំឱ្យធ្វើការងារជាទម្ងន់ ឱ្យរស់នៅក្នុងស្ថានភាពអមនុស្សធម៌ និងការសម្លាប់ដោយខុសច្បាប់នៅត្រពាំងថ្ម ដែលជាទំនប់ និង អាងទឹកសិប្បនិម្មិតដ៏ធំមួយ នៅក្នុងស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ។ ទំនប់នេះត្រូវបានកសាងឡើងនៅក្នុងឆ្នាំ ១៩៧៥ និង ១៩៧៦ ដោយប្រជាជនដែលប្រមូលមកពីភូមិនានានៅជុំវិញទីនោះ រួមទាំងប្រជាជនជម្លៀសជាច្រើនមកពីភ្នំពេញផង។ ពួកអ្នកធ្វើពលកម្មដោយបង្ខំជាច្រើនពាន់នាក់បានស្លាប់ ដោយខ្លះស្លាប់ដោយអត់បាយ និងខ្លះស្លាប់ដោយគេសម្លាប់។ មនុស្សប្រមាណច្រើនរយនាក់ ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខក្បែរនោះ។ ជនរងគ្រោះមកពីគ្រប់ទិសទីនៃស្រុក រួមមានបញ្ញវន្ត និង អតីតមន្ត្រីសាធារណរដ្ឋខ្មែរផង។ **#៤៦** | ក្នុងរយៈពេល៤ឆ្នាំដែលពួកគេកាន់អំណាច បនប៉ុល ពត អៀង សារី បានប្រើវិធីធ្វើទារុណកម្ម និងសម្លាប់មនុស្សយ៉ាងព្រៃផ្សៃបំផុត។ **#VIII** |
| **ភូមិភាគបស្ចិម - កំពង់ឆ្នាំង** | |
| បក្សកុម្មុនីស្តកម្ពុជាបានបង្ខំឲ្យពួកអ្នកជាប់ឃុំដោយខុស | ក្នុងរយៈពេល៤ឆ្នាំដែលពួកគេកាន់អំណាច |

| | |
|---|---|
| ច្បាប់រាប់សិបពាន់នាក់ធ្វើការស្ថាបនាព្រលានយន្តហោះមួយនៅជិតឃុំក្រាំងលាវ ស្រុករលៀផ្អៀ ខេត្តកំពង់ឆ្នាំង ភូមិភាគបស្ចឹម ពួកអ្នកជាប់ឃុំត្រូវបានបង្ខំឱ្យធ្វើការតាំងពីព្រឹកព្រលឹមរហូតដល់យប់ជ្រៅ។ ការងារនេះធ្ងន់ ហើយសុទ្ធតែធ្វើដោយដៃ។ របបអាហារមិនគ្រប់គ្រាន់ ហើយកម្មកររអត់បាយបន្តិចម្តងៗ។ ការចាប់ខ្លួនបានធ្វើជាបន្តបន្ទាប់ អ្នកណាធ្វើអ្វីខុស ត្រូវនាំខ្លួនទៅឆ្ងាយដើម្បីសម្លាប់ចោល។ ប្រជាជនដែលបាត់ខ្លួនត្រូវបានជំនួសជាប្រចាំដោយ អ្នកជាប់ឃុំថ្មី។ **#៤៧** | បនប៉ុល ពត អៀង សារី បានប្រើវិធីធ្វើទារុណកម្ម និងសម្លាប់មនុស្សយ៉ាងព្រៃផ្សៃបំផុត។ **#VIII** |
| **តំបន់ស្វយ័តភ្នំពេញ - មន្ទីរ ស-២៤ (ព្រៃ ស)** | |
| មន្ទីរ ស-២៤ (ដែលគេស្គាល់ផងដែរថា ព្រៃស) ស្ថិតនៅក្នុងភូមិតាឡី ស្រុកចេក និងបាគូ ឃុំព្រៃស ស្រុកដង្កោ ភ្នំពេញ គឺជាកន្លែងអមនុស្សធម៌ហើយជាកន្លែងដែលមនុស្សប្រុសស្រី ត្រូវបានដាក់ឃុំឃាំងដោយខុសច្បាប់ និងត្រូវបានបង្ខំឱ្យលើកទំនប់ជីកប្រឡាយ និងធ្វើស្រែ។ ការធ្វើពលកម្មដោយបង្ខំបានចាប់ផ្តើមពីម៉ោង ៥ ព្រឹក ហើយធ្វើការរហូតដល់ម៉ោង ១០ យប់។ នៅពេលយប់ ពួកអ្នកជាប់ឃុំត្រូវបានចាក់សោរឱ្យនៅក្នុងផ្ទះរួម និងផ្តល់ម្ហូបអាហារមិនគ្រប់គ្រាន់ ។ អ្នកណាមិនអាចធ្វើការ ឬមិនចង់ធ្វើការត្រូវទទួលរងការរំលោភលើរូបរាងកាយជាប្រព័ន្ធ ហើយត្រូវអ្នកយាមមន្ទីរនាំខ្លួនចេញទៅ ហើយមិនដែលឃើញត្រឡប់មកវិញទាល់តែសោះ។ **#៤៨** | ក្នុងរយៈពេល៤ឆ្នាំដែលពួកគេកាន់អំណាច បនប៉ុល ពត អៀង សារី បានប្រើវិធីធ្វើទារុណកម្ម និងសម្លាប់មនុស្សយ៉ាងព្រៃផ្សៃបំផុត។ **#VIII** |
| **ការសម្លាប់ ការធ្វើទារុណកម្ម និងការ** | |

| **រំលោភបំពានផ្នែករាងកាយនិងស្មារតី** | |
| --- | --- |
| **ភ្នំពេញ - មន្ទីរ ស-២១** | |
| មន្ទីរ ស-២១ ស្ថិតនៅតាមផ្លូវលេខ ១០៣ សង្កាត់បឹងកេងកងទី ៣ ខ័ណ្ឌចំការមន ភ្នំពេញ គឺជាមជ្ឈមណ្ឌលសន្តិសុខសំខាន់ជាងគេបំផុត។ ពួកអ្នកជាប់ឃុំរាប់ពាន់នាក់ ត្រូវបានស្ថិតក្នុងស្ថានភាពអមនុស្សធម៌ ការរំលោភលើរូបរាងកាយ ការធ្វើទារុណកម្ម និងការសម្លាប់នៅទីនោះ ក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ មន្ទីរ ស-២១ ដែលត្រូវបានស្គាល់ថាជាទួលស្លែងនោះ បានប្រតិបត្តិការតាមការណែនាំ និងក្រោមបញ្ជាផ្ទាល់របស់អាជ្ញាធរជាន់ខ្ពស់បំផុតនៃបក្សកុម្មុយនីស្តកម្ពុជា។ គោលបំណងរបស់ មន្ទីរស-២១ គឺដាក់ឃុំ និងធ្វើទារុណកម្មអ្នកទោស ដើម្បីទាញយកចម្លើយសារភាព បន្ទាប់មកពួកគេនឹងត្រូវសម្លាប់។ ចម្លើយសារភាពត្រូវបានបញ្ជូនទៅឱ្យថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យ។ ដោយត្រូវបានកំណត់ថាជាខ្មាំងដ៏អាក្រក់ជាងគេបំផុតរបស់បក្សកុម្មុយនីស្តកម្ពុជា ពួកអ្នកជាប់ឃុំនៅ ស-២១ រួមមាន មេដឹកនាំនយោបាយ និងយោធាជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា ពួកភូមិភាគបូព៌ា និងពាយ័ព្យ កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ជនជាតិបរទេស និងបុគ្គលិកស៊ីវិលនិងយោធាវៀតណាម។<br>**#៤៩** | ក្នុងរយៈពេល៤ឆ្នាំដែលពួកគេកាន់អំណាច បនប៉ុល ពត អៀង សារី បានប្រើវិធីធ្វើទារុណកម្ម និងសម្លាប់មនុស្សយ៉ាងព្រៃផ្សៃបំផុត។<br>**#VIII**<br>ទារុណកម្មនៅមន្ទីរស-២១៖ សាក្សីបាននិយាយថា ការរំលោភសេពសន្ថវៈ ការឆក់ខ្សែភ្លើង ការចងព្យួរជើងឡើងលើ ការដកក្រចកដៃ ការយកថង់ប្លាស្ទិកច្រកក្បាលឲ្យថប់ដង្ហើម យកក្រណាត់គ្របមុខរួចចាក់ទឹកពីលើឲ្យថប់ដង្ហើម។<br>**#VIII** |
| ពួកអ្នកជាប់ឃុំនៅមន្ទីរស-២១ ត្រូវបានគេដាក់ខ្នោះជើងបង្ខំឱ្យដេកលើឥដ្ឋទទេក្នុងលក្ខណៈតូចចង្អៀតយ៉ាងខ្លាំង និងបង្អត់បាយដោយចេតនា។ ពួកគេត្រូវដាក់ឱ្យស្ថិតនៅក្រោមការឃាមកាមដោយអ្នកយាមមានអាវុធគ្រប់ | ទារុណកម្មនៅមន្ទីរស-២១៖ សាក្សីបាននិយាយថា ការរំលោភសេពសន្ថវៈ ការឆក់ខ្សែភ្លើង ការចងព្យួរជើងឡើងលើ ការដកក្រចកដៃ ការយកថង់ប្លាស្ទិកច្រកក្បាលឲ្យថប់ដង្ហើម យកក្រណាត់គ្រប |

| | |
|---|---|
| ពេលវេលា ហើយវិន័យត្រូវអនុវត្តជាដាច់ខាត។ ពួកអ្នកទោសមិនត្រូវបានអនុញ្ញាតឱ្យនិយាយរកគ្នា ហាត់ប្រាណឬលុបលាងខ្លួនប្រាណទេ។ ពួកអ្នកទោសជាច្រើនបានផ្តាក់ខ្លួនឈឺ ខណៈត្រូវបានឃុំខ្លួននៅមន្ទីរស-២១។<br>**#៥១** | មុខរួចចាក់ទឹកពីលើឲ្យថប់ដង្ហើម។<br>**#VIII** |
| ពួកអ្នកជាប់ឃុំភាគច្រើនលើសលប់ ត្រូវទទួលរងទារុណកម្មដើម្បីបង្ខំទាញយកចម្លើយសារភាព។ វិធីធ្វើទារុណកម្មរួមមាន: ការវាយដំនឹងព្រនង់ ខ្សែភ្លើង និងអារុធ វាយនឹងរំពាត់ខ្សែតី ការសម្លាប់ដោយអគ្គិសនី ដុតនឹងអំពូលភ្លើងអគ្គីសនី ចាក់ឬដកក្រចកដៃក្រចកជើង ជ្រមុជក្បាលក្នុងធុងទឹក បញ្ច្រកក្បាលនឹងថង់ប្លាស្ទិក ចងព្យួរជើងឡើងលើ និងបង្ខំឱ្យស៊ីលាមកនិងផឹកទឹកនោម។ ភាពធ្ងន់ធ្ងរនៃទារុណកម្ម នឹងកាន់តែបង្កើនឡើងថែមទៀត ចំពោះជនជាប់ឃុំបដិសេធមិនព្រមឆ្លើយសារភាពឱ្យបានសមរម្យដែលជាទូទៅ ចំពោះករណីដែលចម្លើយសារភាពមើលទៅរៀបរាប់មិនគ្រប់គ្រាន់ ឬមានការខកខានមិនបានប្រាប់ឈ្មោះខ្មាំងផ្សេងទៀត។ ចម្លើយសារភាពជាច្រើន តែងមានចំណាររបស់បុគ្គលិកស-២១ ទាក់ទិនទៅនឹងការប្រើទារុណកម្ម។<br>**#៥២** | ទារុណកម្មនៅមន្ទីរស-២១៖ សាក្សីបាននិយាយថា ការរំលោភសេពសន្ថវៈ ការឆក់ខ្សែភ្លើង ការចងព្យួរជើងឡើងលើ ការដកក្រចកដៃ ការយកថង់ប្លាស្ទិកច្រកក្បាលឲ្យថប់ដង្ហើម យកក្រណាត់គ្របមុខរួចចាក់ទឹកពីលើឲ្យថប់ដង្ហើម។<br>**#VIII** |
| បុគ្គលិក ស-២១ តែងតែវាយអ្នកជាប់ឃុំជាទៀងទាត់។ ពួកអ្នកជាប់ឃុំ ត្រូវបានទទួលរងនូវអំពើឃ័យង់ឃ្នងដទៃទៀត ក្នុងនេះរួមមាន ការបូមយកឈាមដោយបង្ខំ និងការធ្វើពិសោធន៍ផ្នែកពេទ្យដទៃទៀត បង្ខំអ្នកជាប់ឃុំឱ្យសំពះរូបភ្ញៅ និងបង្ខំអ្នកជាប់ឃុំឱ្យវាយគ្នាឯង។ | ទារុណកម្មនៅមន្ទីរស-២១៖ សាក្សីបាននិយាយថា ការរំលោភសេពសន្ថវៈ ការឆក់ខ្សែភ្លើង ការចងព្យួរជើងឡើងលើ ការដកក្រចកដៃ ការយកថង់ប្លាស្ទិកច្រកក្បាលឲ្យថប់ដង្ហើម យកក្រណាត់គ្របមុខរួចចាក់ទឹកពីលើឲ្យថប់ដង្ហើម។ |

| | |
|---|---|
| អំពើដ៏យង់ឃ្នងបែបនេះ ត្រូវបានធ្វើតាមទំនើងចិត្តនិងដោយគ្មានរើសអើងឡើយ បង្កើតឱ្យមានបរិយាកាសភ័យរន្ធត់នៅក្នុង ស-២១។ ដោយដាក់ឃុំឃាំងក្នុងលក្ខណៈអមនុស្សធម៌ដូចគ្នានឹងបុរសដែរនោះ ស្ត្រី និងកុមារ ក៏ត្រូវបានសួរចម្លើយ វាយដំ ធ្វើបាបយ៉ាងយង់ឃ្នង ធ្វើទារុណកម្ម និងសម្លាប់។ ការចាប់ខ្លួននិងការប្រហារជីវិតស្ត្រីជាភរិយានិងកុមារ ត្រូវបានធ្វើឡើងតាមគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលថា "ជីកស្មៅត្រូវជីកទាំងឫស" ។<br>#៥៣ | #VIII |
| ពួកអ្នកជាប់ឃុំនៅ ស-២១ ភាគច្រើនលើសលប់ ត្រូវយកទៅសម្លាប់នៅ ជើងឯក ដែលជាទីកន្លែងមួយស្ថិតនៅចម្ងាយប្រមាណ ១៤ គីឡូម៉ែត្រខាងត្បូងក្រុងភ្នំពេញ។ នៅពេលយប់ ពួកអ្នកជាប់ឃុំត្រូវបានចងមុខនិងនាំខ្លួនទៅកាន់ជើងឯក តាមឡានធំ ចំនួន ៣០-៤០ នាក់ម្តងៗ ដែលនៅទីនោះ ពួកគេត្រូវសម្លាប់ ដោយមធ្យោបាយផ្សេងៗ រួមមានការវាយនឹងដំបងរហូតដល់ស្លាប់។ មនុស្សប្រុស ស្រី និងក្មេងៗ គ្រប់អាយុប្រមាណ៩.០០០នាក់ ត្រូវបានរកឃើញនៅក្នុងរណ្តៅសាកសពរួម។<br>#៥៤ | ក្នុងរយៈពេល៤ឆ្នាំដែលពួកគេកាន់អំណាច បនប៉ុល ពត អៀង សារី បានប្រើវិធីធ្វើទារុណកម្ម និងសម្លាប់មនុស្សយ៉ាងព្រៃផ្សៃបំផុត។<br>#VIII |
| ពួកអ្នកជាប់ឃុំខ្លះបានស្លាប់ក្នុងពេលទទួលរងទារុណកម្ម ឬដោយសារបរិភោគមិនគ្រប់គ្រាន់ ដោយជម្ងឺ ឬលក្ខណៈរស់នៅអមនុស្សធម៌។ អ្នកជាប់ឃុំមួយចំនួនតូចបានធ្វើអត្តឃាត។ នៅពេលរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យដួលរលំ នៅដើមឆ្នាំ ១៩៧៩ អ្នកទោសភាគច្រើនលើសលប់ត្រូវបានដឹកចេញទៅដោយឡានធំៗ | ក្នុងរយៈពេល៤ឆ្នាំដែលពួកគេកាន់អំណាច បនប៉ុល ពត អៀង សារី បានប្រើវិធីធ្វើទារុណកម្ម និងសម្លាប់មនុស្សយ៉ាងព្រៃផ្សៃបំផុត។<br>#VIII |

| | |
|---|---|
| ដើម្បីសម្លាប់ចោល។ ពួកអ្នកទោសឋានៈខ្ពស់ត្រូវសម្លាប់នៅនឹងកន្លែងដែលពួកគេជាប់ឃុំ ជាប់ចំណង ឬជាប់ច្រវ៉ាក់ទៅនឹងគ្រែរបស់ពួកគេ។ មានតែអ្នកជាប់ឃុំមួយចំនួនតូចប៉ុណ្ណោះដែលនៅរស់រានមានជីវិត។<br>**#៥៥** | |
| **ភូមិភាគបស្ចិម - ព្រៃត្រពាំងអំពិល** | |
| ក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ មន្ត្រីបក្សកុម្មុយនីស្តកម្ពុជា បានសម្លាប់មនុស្សប្រហែល ១០ ០០០ នាក់ នៅព្រៃត្រពាំងអំពិល ស្ថិតនៅជិតភូមិជុំទាវជ្រែងថ្មី ស្រុកសាមគ្គីមានជ័យ (អតីតជាផ្នែកនៃស្រុកកំពង់ត្រឡាច) ខេត្តកំពង់ឆ្នាំង ភូមិភាគបស្ចិម។ បញ្ចូលក្នុងនេះដែរ គឺមនុស្សមួយចំនួន ដែលចាប់នៅភូមិជុំទាវជ្រែងថ្មី និងនាំយកទៅកាន់ត្រពាំងអំពិល ដែលនៅទីនោះពួកគេត្រូវបានកំណត់ថា ជាខ្មាំងរបស់កម្ពុជាប្រជា-ធិបតេយ្យ និងសម្លាប់ចោល។ មន្ត្រីបក្សកុម្មុយនីស្តកម្ពុជាដែលត្រឡប់មកពីកន្លែងប្រហារជីវិតវិញ ត្រូវបានឃើញនាំយកមកជាមួយនូវសំលៀកបំពាក់ និងឧបករណ៍ផ្សេងៗ ដូចជាចបកាប់ជាដើម។ អ្នកជាប់ឃុំភេទស្រី ត្រូវបានរំលោភមុននឹងសម្លាប់។ ទីតាំងនោះមានរណ្តៅចំនួនប្រមាណ ៥០០ រណ្តៅ ក្នុងមួយរណ្តៅៗ មានសាកសពពី ២០ ទៅ ៥០ នាក់។<br>**#៥៦** | ក្នុងរយៈពេល៤ឆ្នាំដែលពួកគេកាន់អំណាច បនប៉ុល ពត អៀង សារី បានប្រើវិធីធ្វើទារុណកម្ម និងសម្លាប់មនុស្សយ៉ាងព្រៃផ្សៃបំផុត។ (ការវាយជនរងគ្រោះសម្លាប់ទាំងជាប់ចំណងរួច រុញពួកគេទម្លាក់ក្នុងរណ្តៅហើយយកដីលុបពីលើ, អារក, វះពោះយកថ្លើមស៊ី, យកឈើស្រួច ឬគ្រាប់M៧៩ បុកទម្លុះទ្វារមាសស្ត្រីទាល់តែស្លាប់, សម្លាប់មនុស្សដោយយកត្រាត់ទ័រកិនពីលើ, ឆក់ផ្តាច់ជីវិតដោយចរន្តអគ្គីសនី, សម្លាប់ដោយប្រើគ្រឿងផ្ទុះ, កប់ឬដុតទាំងរស់ ឬបោះឲ្យក្រពើស៊ី, កូនក្មេងត្រូវច្រកក្នុងថង់ប្លាស្ទិកយកទៅព្យួរលើដើមឈើ, ដុតទារកទាំងរស់, បោះទារកទៅលើមេឃហើយយកចំពុះទុងទ្រ, ចាប់ហែកជើងទារក, វះពោះទាំងរស់, កាត់ក្បាលមនុស្ស )<br>#VIII |
| **ភូមិភាគបស្ចិម - មន្ទីរសន្តិសុខ "ព្រៃដំរីស្រុត"** | |
| បក្សកុម្មុយនីស្តកម្ពុជា បានដាក់ឃុំមនុស្សជាច្រើនដោយខុសច្បាប់ ដែលពួកគេមួយចំនួនធំបានស្លាប់ដោយសារ | ក្នុងរយៈពេល៤ឆ្នាំដែលពួកគេកាន់អំណាច បនប៉ុល ពត អៀង សារី បានប្រើវិធីធ្វើទារុណកម្ម |

| | |
|---|---|
| អត់បាយ ការធ្វើការងារហួសកម្លាំង ឬដោយការសម្លាប់ នៅមន្ទីរសន្តិសុខព្រៃដំរីស្រុត ឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ភូមិភាគបស្ចឹម។ **#៥៧** | និងសម្លាប់មនុស្សយ៉ាងព្រៃផ្សៃបំផុត។ **#VIII** |
| ពួកអ្នកទោសកំរិត "ស្រាល" ត្រូវបានអនុញ្ញាតឱ្យដើរដោយឥតដាក់ខ្នោះដៃ ប៉ុន្តែចំពោះពួកអ្នកទោសកំរិតធ្ងន់ត្រូវដាក់ខ្នោះដៃផងខ្នោះជើងផង។ ពួកអ្នកទោសកំរិតស្រាល ត្រូវបង្ខំឱ្យធ្វើការពីម៉ោង ៦ ព្រឹក ដល់ម៉ោង ១៧ ដោយមានសំរាក ៩០ នាទី។ ពួកអ្នកទោសកំរិតធ្ងន់ធ្វើការដោយឥតសំរាកទេ។ ប្រសិនបើជាថ្ងៃពេញបូរមី ពួកអ្នកទោសត្រូវធ្វើការទាំងយប់ផងដែរ។ អ្នកទោសភាគច្រើនបានស្លាប់ ដោយសារអត់បាយ និងធ្វើការហួសកម្លាំង តែក៏មានអ្នកទោសដែលគេសម្លាប់ដែរ។ ពួកអ្នកទោសនៅរស់ ត្រូវកប់ខ្មោចអ្នកស្លាប់ក្នុងរណ្តៅក្បែរទីនោះ។ **#៥៨** | ក្នុងរយៈពេល៤ឆ្នាំដែលពួកគេកាន់អំណាច បនប៉ុល ពត អៀង សារី បានប្រើវិធីធ្វើទារុណកម្ម និងសម្លាប់មនុស្សយ៉ាងព្រៃផ្សៃបំផុត។ **#VIII** |
| **តំបន់ស្វយ័តកំពង់សោម - មន្ទីរសន្តិសុខ "កោះខ្យង"** | |
| ក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ប្រជាជនរាប់ពាន់នាក់ត្រូវបានដាក់ឃុំ ធ្វើទារុណកម្ម ហើយបន្ទាប់មកសម្លាប់ចោល ដោយពួកមន្ត្រីបក្សកុម្មុយនីស្តកម្ពុជា នៅមន្ទីរសន្តិសុខកោះខ្យង ស្ថិតនៅភូមិកោះខ្យង សង្កាត់អូរជ្រៅ ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ។ កន្លែងនេះគឺជាគុកមជ្ឈិមរបស់តំបន់ ៣៧ ហើយ ធំជាងមន្ទីរឃុំឃាំងដទៃទៀតក្នុងតំបន់នេះ។ ពួកអ្នកទោសត្រូវបង្ខំឱ្យដេកផ្ទាល់ដី ច្រវាក់ច្រវាក់ជាមួយ អាចម៍នោមរបស់ពួកគេ។ ដង្កូវវារលើខ្លួនរបស់ពួកគេ។ ពួកអ្នកទោសត្រូវបានសួរ | ក្នុងរយៈពេល៤ឆ្នាំដែលពួកគេកាន់អំណាច បនប៉ុល ពត អៀង សារី បានប្រើវិធីធ្វើទារុណកម្ម និងសម្លាប់មនុស្សយ៉ាងព្រៃផ្សៃបំផុត។ **#VIII** |

| | |
|---|---|
| ចម្លើយ ៧ ថ្ងៃម្តង ហើយជារៀងរាល់ថ្ងៃ មានអ្នកទោសស្លាប់ ៥ ឬ ៦ នាក់ ដោយសារជម្ងឺ អត់ឃ្លាន ឬការបង្ខំសួរចម្លើយ។ មន្ត្រីបក្សកុម្មុយនីស្តកម្ពុជា សម្លាប់មនុស្សដោយមិនខ្វល់ពីអាយុ ឬភេទ ហើយក្នុងករណីខ្លះ ជនរងគ្រោះនៅមន្ទីរឃុំឃាំងត្រូវបានបោះចូលទៅក្នុងអណ្តូងមួយ បន្ទាប់ពីបានចាក់ពួកគេនឹងចំពុះទុង។ មានរណ្តៅកប់ខ្មោចពាក់ព័ន្ធគ្នាចំនួន ២ ស្ថិតនៅចម្ងាយប្រមាណ ១៥ គីឡូម៉ែត្រពីគ្នា។ **#៥៩** | |
| **ភូមិភាគនិរតី - មន្ទីរសន្តិសុខ "ក្រាំងតាចាន់"** | |
| ចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៨ មន្ត្រីបក្សកុម្មុយនីស្តកម្ពុជា បានសម្លាប់មនុស្ស ប្រហែលជា ១២ ០០០ នាក់ នៅមន្ទីរសន្តិសុខ និងមន្ទីរឃុំឃាំង នៅក្រាំងតាចាន់ ឃុំគូស ស្រុកត្រាំកក់ ខេត្តតាកែវ ភូមិភាគនិរតី។ ពួកអ្នកជាប់ឃុំ រួមមាន "ប្រជាជនថ្មី" គ្រួសារអតីតទាហាន និងប្រជាជនផ្សេងៗ ក្នុងខេត្តតាកែវ។ ពួកអ្នកជាប់ឃុំត្រូវបានដាក់ខ្នោះគ្រប់ពេលវេលា និងសម្លាប់តាមកាលកំណត់ជាទៀងទាត់ ក្នុងនោះរួមមានការវាយរហូតដល់ស្លាប់ផង។ មុនការដួលរលំនៃកម្ពុជាប្រជាធិបតេយ្យបន្តិច ក្នុងឆ្នាំ ១៩៧៨ ពួកអ្នកទោសនៅសល់ទាំងអស់ត្រូវសម្លាប់។ ការគាស់ផ្នូរក្រោយឆ្នាំ ១៩៧៩ សំណល់សាកសពអ្នកទោសប្រមាណ ២០០០ នាក់ ត្រូវបានរកឃើញនៅទីនោះឬក្បែរនោះ។ សំណល់សាកសពមនុស្សជាង ១០ ០០០ នាក់ទៀត ស្ថិតនៅក្នុងរណ្តៅសាកសពរួមដែលមិនទាន់គាស់ចេញនៅក្នុងតំបន់នេះ។ | ក្នុងរយៈពេល៤ឆ្នាំដែលពួកគេកាន់អំណាច បនប៉ុល ពត អៀង សារី បានប្រើវិធីធ្វើទារុណកម្ម និងសម្លាប់មនុស្សយ៉ាងព្រៃផ្សៃបំផុត។ #VIII |

| #៦០ | |
|---|---|
| **ភូមិភាគនិរតី - មន្ទីរសន្តិសុខ "សង់"** | |
| មនុស្សរាប់ពាន់នាក់ត្រូវបានឃុំខ្លួនដោយខុសច្បាប់ និង រស់នៅដោយអមនុស្សធម៌ បន្ទាប់មក ត្រូវបានសម្លាប់ ដោយមន្ត្រីបក្សកុម្មុយនីស្តកម្ពុជា ចាប់ពីដើមឆ្នាំ ១៩៧៧ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ ១៩៧៩ នៅមន្ទីរសន្តិសុខសង់ នៅស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ភូមិភាគនិរតី។ នៅក្នុងឆ្នាំ ១៩៦៣ កន្លែងនោះត្រូវបានសាងសង់ដើម្បី ធ្វើជាអនុវិទ្យាល័យសម្រាប់បណ្តុះបណ្តាលគ្រូបង្រៀន ហើយនៅដើមឆ្នាំ ១៩៧៧ វាបានក្លាយជាមន្ទីរសន្តិសុខ។ ជាធម្មតា មនុស្សជាប់ឃុំប្រមាណ ៥០០ នាក់ ត្រូវបាន បង្ខំឱ្យធ្វើការដោយកម្លាំង និងត្រូវបានបង្អត់បាយជា ប្រព័ន្ធនៅក្នុងមន្ទីរសន្តិសុខនេះ។ អ្នកទោសជាច្រើន នាក់ជាអតីតកម្មាភិបាល បក្សកុម្មុយនីស្តកម្ពុជា ដែល ត្រូវបានចោទថាជាខ្មាំង និងក្រុមគ្រួសាររបស់ពួកគេ។ ពួកអ្នកទោសត្រូវស្លាប់ដោយការអត់បាយនិងជម្ងឺជា រឿយ ហើយពួកអ្នកជាប់ឃុំប្រមាណពី ១៥ ទៅ ២០ នាក់ ត្រូវបាននាំយកទៅវាលពិឃាតនៅក្បែរទីនោះ និង សម្លាប់ចោលរាល់យប់។ ពួកគេត្រូវជំនួស ដោយ អ្នកទោសថ្មីដែលមកដល់ជារៀងរាល់អាទិត្យ ឬរាល់ ១០ ថ្ងៃម្តង។ រណ្តៅកប់ខ្មោចរួមទាក់ទងនឹងកន្លែងនេះ ដែលត្រូវបានគាស់ចេញនៅក្រោយឆ្នាំ ១៩៧៩ ឃើញ សាកសពរាប់ពាន់នាក់ និងរណ្តៅសាកសពរួមផ្សេង ទៀតនៅម្តុំនោះ ដែលមិនទាន់គាស់ចេញទេ។<br>#៦១ | ក្នុងរយៈពេល៤ឆ្នាំដែលពួកគេកាន់អំណាច បនប៉ុល ពត អៀង សារី បានប្រើវិធីធ្វើទារុណកម្ម និងសម្លាប់មនុស្សយ៉ាងព្រៃផ្សៃបំផុត។<br>#VIII |

| | |
|---|---|
| **ភូមិភាគពាយ័ព្យ - កន្លែងសម្លាប់មនុស្ស "ទួលពោធិជ្រៃ"** | |
| មន្ត្រីបក្សកុម្មុយនីស្តកម្ពុជា នៅទួលពោធិជ្រៃ បានសម្លាប់មនុស្សប្រមាណ ១០ ០០០ នាក់ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ វាលពិឃាតទួលពោធិជ្រៃ ស្ថិតនៅក្បែរ អតីតមូលដ្ឋានយោធាសាធារណរដ្ឋខ្មែរនៅស្រុកកណ្តៀង ខេត្តពោធិ៍សាត់ ភូមិភាគពាយ័ព្យ។ ពុំមានមន្ទីរឃុំឃាំងទេនៅទីនោះ។ ប្រជាជនត្រូវបានដឹកទៅកាន់ទីនោះតាមឡានធំៗ រួចដើរទៅកាន់វាលពិឃាត ហើយត្រូវបានសម្លាប់ភ្លាមៗ។ រណ្តៅសាកសពរួមដែលមិនទាន់ប៉ះពាល់នៅកន្លែងនោះអាចមានសាកសពជនរងគ្រោះ ចំនួន ១០ ០០០នាក់ ឬច្រើនជាងនេះ។<br>**#៦២** | ក្នុងរយៈពេល៤ឆ្នាំដែលពួកគេកាន់អំណាច បនប៉ុល ពត អៀង សារី បានប្រើវិធីធ្វើទារុណកម្ម និងសម្លាប់មនុស្សយ៉ាងព្រៃផ្សៃបំផុត។<br>**#VIII** |
| **តំបន់ក្រចេះ - មន្ទីរសន្តិសុខ "គោកក្ដួច"** | |
| បក្សកុម្មុយនីស្តកម្ពុជា បានធ្វើប្រតិបត្តិការនៅមន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្សនៅគោកក្ដួច ស្រុកសំបូរ តំបន់ក្រចេះ។ អ្នកទោសនៅគោកក្ដួច រួមមានអតីតមន្ត្រីសាធារណរដ្ឋខ្មែរ អតីតកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា និងពួកអ្នកដែលត្រូវចោទថាបានប្រព្រឹត្តខុសសីលធម៌។ ពួកអ្នកទោស ត្រូវដាក់ខ្នោះគ្រប់ពេលវេលា និងទទួលរងទារុណកម្មជាប្រចាំ។ សាក្សីម្នាក់ ដែលធ្លាប់បានធ្វើការនៅការដ្ឋានក្បែរទីនោះធ្លាប់បានកប់ខ្មោចចំនួន ៨៩ នាក់។ ពួកអ្នកទោសមួយចំនួនផ្សេងទៀតក៏ត្រូវបានសម្លាប់ដោយសម្ងាត់ផងដែរ។ | ក្នុងរយៈពេល៤ឆ្នាំដែលពួកគេកាន់អំណាច បនប៉ុល ពត អៀង សារី បានប្រើវិធីធ្វើទារុណកម្ម និងសម្លាប់មនុស្សយ៉ាងព្រៃផ្សៃបំផុត។<br>**#VIII**<br>ការសម្លាប់បំផុតពូជដោយមិនរើសមុខ ទៅលើនាយទាហាន ពលទាហាននិងអ្នករដ្ឋការរបស់របបមុន ព្រមទាំងគ្រួសាររបស់គេ។<br>**#I.១** |

| #៦៣ | |
|---|---|
| **តំបន់មណ្ឌលគីរី - មន្ទីរសន្តិសុខ "ភ្នំក្រោល"** | |
| ពីចុងឆ្នាំ ១៩៧៧ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ប្រជាជនដែលត្រូវបានសន្មត់ថាជាជនក្បត់ ត្រូវបានចាប់ខ្លួន ហើយត្រូវបានសម្លាប់ដោយមន្ត្រី បក្សកុម្មុយនីស្តកម្ពុជា នៅមន្ទីរសន្តិសុខ ភ្នំក្រោល នៅភូមិ៩ ឃុំស្រែសង្គម ស្រុកកោះញែក ខេត្តមណ្ឌលគីរី។ មុនពេលមន្ទីររដ្ឋបាលតំបន់១០៥ បានក្លាយជាមន្ទីរសន្តិសុខរបស់តំបន់នៅចុងឆ្នាំ១៩៧៧ មន្ទីរនោះគឺជាមន្ទីរសន្តិសុខធំជាងគេបំផុតនៅស្រុកកោះញែក តំបន់មណ្ឌលគីរី។ មនុស្សខ្លះត្រូវបានឃុំខ្លួនដោយសារជាប់ពាក់ព័ន្ធជាមួយអតីតមេដឹកនាំ ដែលត្រូវបានចាត់ទុកថាជាជនក្បត់។ អ្នកទោសត្រូវបានចែកជា ២ ប្រភេទ: អ្នកទោសឋានៈខ្ពស់ និងអ្នកទោសធម្មតា អ្នកទោសឋានៈខ្ពស់ ត្រូវដាក់នៅក្នុងបន្ទប់ជាន់លើ ហើយអ្នកទោសធម្មតា ដាក់ឱ្យនៅផ្ទាល់ដី។ ពួកអ្នកទោសឋានៈខ្ពស់ត្រូវបានដាក់ខ្នោះជើង រីឯអ្នកទោសធម្មតាត្រូវចងជើងបន្តគ្នាពីម្នាក់ទៅម្នាក់ទៀត ហើយដៃត្រូវចងទៅក្រោយ។ នៅពេលយប់ ពួកអ្នកទោសឋានៈខ្ពស់ត្រូវបានដឹកតាមឡានធំៗទៅទិសខាងលិចឆ្ពោះទៅខេត្តក្រចេះ។ អ្នកទាំងនេះបានបាត់ខ្លួនរហូត ហើយត្រូវបានសន្មតថាត្រូវបានសម្លាប់។<br>**#៦៤** | ការបង្ក្រាបដែលមានលក្ខណៈធ្ងន់ធ្ងរ និងការសម្លាប់រង្គាលជាលក្ខណៈប្រព័ន្ធលើបុគ្គលនិងអង្គការដែលសង្ស័យថាប្រឆាំងនឹងរបបនេះ (បោសសម្អាតអង្គការខ្លួនឯងនិងសម្លាប់ជនណាដែលសង្ស័យថាក្បត់ពួកគេ)។<br>**#I.៣** |

| | |
|---|---|
| **ភូមិភាគបូព៌ា - កន្លែងសម្លាប់មនុស្ស "ស្ទឹងតូច"** | ការបង្ក្រាបដែលមានលក្ខណៈធ្ងន់ធ្ងរ និងការសម្លាប់រង្គាលជាលក្ខណៈប្រព័ន្ធលើបុគ្គលនិងអង្គការដែលសង្ស័យថាប្រឆាំងនឹងរបបនេះ (បោសសម្អាតអង្គការខ្លួនឯងនិងសម្លាប់ជនណាដែលសង្ស័យថាក្បត់ពួកគេ)។ **#I.៣** |
| មនុស្សជាច្រើននាក់ ក្នុងនោះរួមមានទាហានភូមិភាគបូព៌ា និងក្រុមគ្រួសាររបស់ពួកគេ ត្រូវបានសម្លាប់ដោយមន្ត្រីបក្សកុម្មុយនីស្តកម្ពុជា នៅស្ទឹងតូច។ ស្ទឹងតូចស្ថិតនៅក្នុងស្រុកពញាក្រែក ខេត្តកំពង់ចាម ភូមិភាគបូព៌ា ដែលមានរណ្តៅសាកសពរួម យ៉ាងហោចណាស់៣។ ជនរងគ្រោះត្រូវបានដាក់ខ្នោះ បង្ខំឱ្យដើរទៅកាន់កន្លែងសម្លាប់ ហើយត្រូវបានសម្លាប់ចោលតែម្តង។ **#៦៥** | ការសម្លាប់បំផុតពូជដោយមិនរើសមុខ ទៅលើនាយទាហាន ពលទាហាននិងអ្នករដ្ឋការរបស់របបមុន ព្រមទាំងគ្រួសាររបស់គេ។ **#I.១** |
| **ភូមិភាគបូព៌ា - មន្ទីរសន្តិសុខ "វត្តធ្លក"** | |
| ជនរងគ្រោះច្រើនប្រមាណ ១៥ ០០០ នាក់ អាចត្រូវបានសួរចម្លើយ និងសម្លាប់នៅមន្ទីរសន្តិសុខវត្តធ្លក ដោយមន្ត្រីបក្សកុម្មុយនីស្តកម្ពុជា។ បក្សកុម្មុយនីស្តកម្ពុជាបានសង់គុកមួយនៅជិតវត្តធ្លក ក្នុងភូមិធ្លក ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ភូមិភាគបូព៌ា។ វាជាមន្ទីរឃុំឃាំងធំជាងគេបំផុត នៅខេត្តស្វាយរៀង។ វាអាចជាគុកសំខាន់របស់តំបន់២៣។ មានរណ្តៅសាកសពចំនួន ៤១ ទាក់ទងនឹងកន្លែងនេះ ដោយរណ្តៅចំនួន៣ ត្រូវបានគាស់ចេញនៅឆ្នាំ១៩៨២។ រណ្តៅទាំង៣នេះ មានសាកសពជាង ៩០០ នាក់ ហើយ រណ្តៅដែលនៅសល់អាចមានសាកសពចំនួនពី ១០ ០០០ ទៅ ១៥ ០០០ នាក់។ | ក្នុងរយៈពេល៤ឆ្នាំដែលពួកគេកាន់អំណាច បនប៉ុល ពត អៀង សារី បានប្រើវិធីធ្វើទារុណកម្ម និងសម្លាប់មនុស្សយ៉ាងព្រៃផ្សៃបំផុត។ **#VIII** |

| | |
|---|---|
| **#៦៦** | |
| **ភូមិភាគឦសាន្ត - ភូមិ ៣** | |
| នៅចន្លោះឆ្នាំ ១៩៧៧ និងឆ្នាំ ១៩៧៩ មនុស្សប្រមាណ ២០០០ នាក់ ត្រូវស្លាប់ដោយអត់បាយ និងដោយការសម្លាប់នៅមន្ទីរសន្តិសុខក្បែរភូមិ ៣ ស្រុកបានលុង ខេត្តរតនគីរី ភូមិភាគឦសាន្ត។ មន្ទីរសន្តិសុខនេះ ត្រូវបានសាងសង់ឡើងនៅក្នុងឆ្នាំ ១៩៦២ និងប្រតិបត្តិការរហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ ១៩៧៩។ ពួកអ្នកទោសត្រូវបានបង្ខំឱ្យធ្វើការជាទម្ងន់រាល់ថ្ងៃ ប៉ុន្តែមិនឱ្យបាយហូបគ្រប់គ្រាន់ទេ។ ត្រឹមឆ្នាំ១៩៧៧ ពួកអ្នកជាប់ឃុំទទួលបានរបបអង្ករមួយកំប៉ុងសម្រាប់គ្នា ១០ នាក់ ក្នុងមួយពេល។ នៅពេលយប់ ពួកអ្នកទោសត្រូវបានដឹកតាមឡានធំៗ នាំចេញទៅ។ ពួកអ្នកជាប់ឃុំនៅគុកនេះជឿថា ពួកអ្នកទោសដែលបានដឹកចេញទៅទាំងនោះគឺត្រូវបានគេសម្លាប់។ រណ្តៅសាកសពរួមធំៗ ២ ស្ថិតនៅក្បែរមន្ទីរសន្តិសុខនេះ មានសាកសពប្រមាណ ៦០០ នាក់ ហើយនៅមានរណ្តៅសាកសពរួមតូចៗផ្សេងទៀតជាច្រើនដែលមិនទាន់គាស់ចេញនៅកន្លែងនេះ អាចមានសាកសពរហូតដល់ទៅ ២០០០ នាក់។ **#៦៧** | ក្នុងរយៈពេល៤ឆ្នាំដែលពួកគេកាន់អំណាច បនប៉ុល ពត អៀង សារី បានប្រើវិធីធ្វើទារុណកម្ម និងសម្លាប់មនុស្សយ៉ាងព្រៃផ្សៃបំផុត។ **#VIII** |
| **ភូមិភាគពាយ័ព្យ - វត្តគីរីរម្យ** | |
| ចន្លោះឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៩ មនុស្សប្រមាណ ១៥ ០០០ នាក់ អាចត្រូវបានសម្លាប់ដោយមន្ត្រីបក្សកុម្មុយនីស្តកម្ពុជា នៅមន្ទីរសន្តិសុខវត្តគីរីរម្យ ភ្នំគីរីរម្យ ស្រុកបាណន់ ខេត្តបាត់ដំបង ភូមិភាគពាយ័ព្យ។ មនុស្សទាំង | ក្នុងរយៈពេល៤ឆ្នាំដែលពួកគេកាន់អំណាច បនប៉ុល ពត អៀង សារី បានប្រើវិធីធ្វើទារុណកម្ម និងសម្លាប់មនុស្សយ៉ាងព្រៃផ្សៃបំផុត។ **#VIII** |

| | |
|---|---|
| ឡាយត្រូវបានដឹកតាមរថយន្តទៅទីនោះ និងដាក់គុក។ រាល់ថ្ងៃ មានអ្នកជាប់ឃុំមួយក្រុមត្រូវបានសួរចម្លើយ។ ក្រោយបញ្ចប់ការសួរចម្លើយហើយ ពួកគេត្រូវបានសម្លាប់ចោល។ ក្មេងៗត្រូវបានសម្លាប់ដោយមិនសួរចម្លើយ។ ជនរងគ្រោះត្រូវបានសម្លាប់នៅក្នុងរូងភ្នំជាច្រើនក្បែរទីនោះ។<br>**#៦៨** | |
| **ភូមិភាគបូព៌ា - ជនជាតិវៀតណាមនៅក្នុងខេត្តព្រៃវែង និងនៅប្រទេសវៀតណាម** | |
| បក្សកុម្មុយនីស្តកម្ពុជាបានចូលរួមក្នុងនយោបាយលុបបំបាត់ប្រជាជនវៀតណាមទាំងអស់នៅក្នុងខេត្តព្រៃវែងតាមការសម្លាប់ចោល។ ផ្នែកមួយនៃនយោបាយនេះតម្រូវថាឪពុកជាជនជាតិវៀតណាមបានរៀបការជាមួយម្តាយជាខ្មែរ "ត្រូវនាំខ្លួន" និងសម្លាប់ ហើយតម្រូវផងដែរឱ្យនាំខ្លួន និងសម្លាប់ទាំងម្តាយទាំងកូន បើម្តាយជាវៀតណាម។ នយោបាយស្រដៀងគ្នានេះត្រូវបានអនុវត្តនៅខេត្តស្វាយរៀង។<br>**#៦៩** | ការលុបបំបាត់សាសនា ការសម្លាប់បំផុតពូជដែលមានលក្ខណៈជាប្រព័ន្ធលើជនជាតិភាគតិច។<br>**#II** |
| បន្ថែមពីលើនេះ បក្សកុម្មុយនីស្តកម្ពុជា បានចាប់យកនយោបាយសម្លាប់វៀតណាម ដែលពួកគេជួបក្នុងពេលវាយលុកចូលក្នុងប្រទេសវៀតណាម។ ពួកទាហានបដិវត្តន៍កម្ពុជាបានញុះញង់ឱ្យស្អប់វៀតណាម និងឱ្យសម្លាប់វៀតណាមទាំងអស់ដែលពួកគេជួប។ កងកម្លាំងកម្ពុជាប្រជាធិបតេយ្យ បានបំផ្លាញទ្រព្យសម្បត្តិជនស៊ីវិល ក្នុងនោះមានមន្ទីរពេទ្យ រោងចក្រ ផ្ទះសម្បែង និងទីផ្សារក្នុងទឹកដីវៀតណាម។ កងកម្លាំងវៀតណាម | ការសម្លាប់បំផុតពូជអាណិកជន<br>**#II**<br>អាណិកជនចិន ឬវៀតណាម ត្រូវបានសម្លាប់។<br>**#II** |

| | |
|---|---|
| ក៏បានធ្វើការវាយបកមកលើទឹកដីកម្ពុជាវិញ ដូចដែលកងកម្លាំងកម្ពុជាប្រជាធិបតេយ្យបានធ្វើទៅលើប្រទេសវៀតណាមដែរ។ វៀតណាមបានធ្វើការតវ៉ាជាបន្តបន្ទាប់ទៅរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ អំពីការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិដោយកងកម្លាំងកម្ពុជាប្រជាធិប-តេយ្យនៅក្នុងប្រទេសវៀតណាម។ ការប្តឹងផ្តល់ទាំងនេះ ត្រូវបានបញ្ជូនបន្តទៅឱ្យមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ រួមមាន ប៉ុល ពត, **នួន ជា** និង **អៀង សារី**។<br>**#៧០** | |
| **ភូមិភាគឧត្តរចាស់ និងភូមិភាគបូព៌ា** | |
| មនុស្សមួយចំនួនធំត្រូវបានសម្លាប់ ក្នុងពេលធ្វើការបោសសំអាត នៅភូមិភាគឧត្តរ នៅក្នុងឆ្នាំ ១៩៧៦ និងនៅភូមិភាគបូព៌ានៅក្នុងឆ្នាំ ១៩៧៨ ដែលបញ្ជាដោយមេដឹកនាំថ្នាក់មន្ទីរ។ ពេលណានៅក្នុងភូមិភាគមួយត្រូវបានរកឃើញថាអាចមិនមានភាពស្មោះត្រង់ ដោយឈរលើមូលដ្ឋាននៃចម្លើយសារភាពបានមកដោយបង្ខំដោយការធ្វើទារុណកម្មនៅ ស-២១ ជាធម្មតាមេដឹកនាំភូមិភាគនោះត្រូវចាប់ខ្លួន ធ្វើទារុណកម្ម និងសម្លាប់។<br>**#៧១** | ការបង្ក្រាបដែលមានលក្ខណៈធ្ងន់ធ្ងរ និងការសម្លាប់រង្គាលជាលក្ខណៈប្រព័ន្ធលើបុគ្គលនិងអង្គការដែលសង្ស័យថាប្រឆាំងនឹងរបបនេះ។<br>**#I.៣** |
| **ពុទ្ធសាសនិកជននៅក្នុងខេត្តកណ្តាល ក្រចេះ កំពត ស្ទឹងត្រែង និងបាត់ដំបង** | |
| ពុទ្ធសាសនិកជនត្រូវទទួលរងការរើសអើង តាមនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលតម្រូវឱ្យលុបបំបាត់សាសនាទាំងអស់។ ជាពិសេសព្រះសង្ឃ | ការសម្លាប់រង្គាលមេដឹកនាំសាសនា សាសនិកជន ការលុបបំបាត់សាសនា ការសម្លាប់បំផុតពូជដែលមានលក្ខណៈជាប្រព័ន្ធលើភាគតិចដោយមិនរើស |

| | |
|---|---|
| ទាំងអស់ត្រូវចាប់ផ្សឹក វត្តជាច្រើនត្រូវធ្វើឱ្យខូចខាត ឬកំទេចចោលតែម្តង ហើយព្រះសង្ឃជាច្រើនអង្គត្រូវបានធ្វើគត់។ នយោបាយនេះត្រូវបានអនុវត្តនៅគ្រប់វត្តទូទាំងកម្ពុជាប្រជាធិបតេយ្យ ក្នុងនេះរួមមាន វត្តចំបក់ ភូមិទួលស្តី ឃុំទួលស្តី ស្រុកចន្ទ្រា ខេត្តស្វាយរៀង វត្តតាគុត និងវត្តម៉ែ ភូមិដៃតូច ឃុំដៃតូច ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល វត្តអន្ទង់វៀន ដែលត្រូវបានគេស្គាល់ថាវត្តមុនីវង្សអន្ទង់វៀន ភូមិអន្ទង់វៀន ឃុំកន្ទួត ស្រុកក្រចេះ ខេត្តក្រចេះ វត្តដំណាក់ត្រយឹង ស្រុកទូកមាស ខេត្តកំពត វត្តជ័យមង្គល ភូមិកំភុន ឃុំកំភុន ស្រុកសេសាន ខេត្តស្ទឹងត្រែង និងវត្តសំរោង ភូមិសំរោង ឃុំសំរោង ស្រុកឯកភ្នំ ខេត្តបាត់ដំបង។<br>**#៧២** | មុខ មិនថាអ្នកណាជាសត្រូវឬមិនមែនជាសត្រូវនោះទេ ក្នុងគោលបំណងដាក់ឲ្យរស់នៅលាយឡំគ្នា, ការសម្លាប់បំផុតពូជអាណិកជន។ (ការបាញ់កាំភ្លើងចូលទៅក្នុងអាគារសាសនា បង្ខំឲ្យអ្នកបួសចាកសិក្ខាបទ ព្រះបដិមាករត្រូវវាយបំបែកចោលអស់ វត្តអារាមត្រូវក្លាយទៅជាទីឃុំឃាំង ឬជំរុំប្រមូលផ្តុំ ឬឃ្លាំងស្តុក ជនអ៊ីស្លាមត្រូវបង្ខំឲ្យស៊ីសាច់ជ្រូក ឬត្រូវសម្លាប់ ហើយបើពួកគេនិយាយភាសាកំណើតខ្លួននឹងត្រូវសម្លាប់ចោល)<br>**#II** |